បរិយាយប័ណ្ណឱសថ
មេត្រល ប្យូរតាមសរសៃឈាម

METRAL

Solution for Infusion
Metronidazole 500mg

I រូបភាពឱសថ :
-ជាឱសថប្រភេទសូលុយស្យុងសំរាប់ចាក់ព្យួរតាមសរសៃឈាម
-១ប្រអប់មាន ១ដបប្លាស្ទិក ចំណុះ 100ml

II សមាសធាតុសំខាន់ : ក្នុង 100ml មាន ៖
-Metronidazole …… 500mg

III គុណសាភាពព្យាបាល :
ឱសថនេះស្ថិតក្នុងក្រម antibacterial ប្រើសំរាប់ព្យាបាលជំងឺឆ្លងច្រើនប្រភេទដូចជា៖
-ជំងឺឆ្លងដោយសារបាក់ទេريا
-ជំងឺឆ្លងក្រៅពោះវៀនដោយសារអាមីប រួមមានជំងឺដំបៅអាប់សែថ្លើមដោយសារអាមីប (amebiasis)
-ជំងឺឆ្លងក្នុងពោះវៀនដោយសារអាមីប (ជំងឺរាករូសដោយសារអាមីប)
-ជំងឺឆ្លងក្នុងប្រដាប់បន្តពូជដោយសារមេរោគ Trichomonas (ជំងឺរលាកទ្វារមាស ជំងឺរលាកដៃស្សរ)
-ជំងឺឆ្លងដោយសារបាក់តេរី Bacteroides spp.
-ជំងឺឆ្លងក្នុងសន្លាក់និងឆ្អឹង
-ជំងឺឆ្លងក្នុងប្រព័ន្ធសរសៃប្រសាទកណ្តាល រួមមានជំងឺរលាកស្រោមខួរក្បាល
-ជំងឺដំបៅអាប់សែក្នុងខួរក្បាល
-ជំងឺរលាកសាច់ដុំបេះដូងដោយសារបាក់តេរី
-ជំងឺរលាកសួត ជំងឺដំបៅអាប់សែក្នុងសួត
-ជំងឺរលាកស្រោមសួត (ខ្នុះលើស្រោមសួត)
-ជំងឺមេរោគសាយភាយក្នុងឈាម
-ជំងឺឆ្លងដោយសារមេរោគ Clostridium spp.
-ជំងឺឆ្លងក្នុងពោះ (ជំងឺរលាកស្រោមពោះ ជំងឺដំបៅអាប់សែថ្លើម)
-ជំងឺឆ្លងក្នុងឆ្អឹងត្រគាក
-ជំងឺរលាកភ្នាសពោះវៀន (ទាក់ទងជាមួយនឹងការប្រើឱសថអង់ទីប៊ីយ៉ូទិក)
-ជំងឺដំបៅក្រពះ-ឃ្យរលាកក្រពះដោយសារមេរោគ Helicobacter pylori
-បង្ការជំងឺឆ្លងក្រោយពេលវះកាត់
-ប្រើក្នុងការព្យាបាលដោយវិទ្យុសកម្មចំពោះអ្នកជំងឺដែលមានជុំសាច់មហារីក

IV ការណែនាំប្រើ:
-អ្នកងាយមានប្រតិកម្មជាមួយ Metronidazole ឬជាមួយនឹងសារធាតុឈ្មីណាមួយនៃឱសថនេះ
-អ្នកជំងឺដែលមានវិបត្តិគ្រាប់ឈាម (ខ្វះគ្រាប់ឈាមក្រហម)
-អ្នកមានជំងឺទាក់ទងជាមួយនឹងប្រព័ន្ធសរសៃប្រសាទកណ្តាល (ជំងឺឆ្កួតជ្រុក)
-អ្នកមានជំងឺខ្សោយមុខងារថ្លើម
-ស្ត្រីមានផ្ទៃពោះ (ក្នុងត្រីមាសទី១)
-ស្ត្រីចំបៅដោះកូន

V ការប្រុងប្រយ័ត្ន:
ការប្រើឱសថនេះត្រូវមានការប្រុងប្រយ័ត្នចំពោះលក្ខណៈដូចខាងក្រោម៖
-ឱសថនេះមិនមានសកម្មភាពប្រយុទ្ធប្រឆាំងថ្នាល់ជាមួយនឹងមេរោគដែលអាចរស់ដោយមានអុកស៊ីហ្សេន (aerobic bacteria) និងមេរោគរស់ដោយគ្មានអុកស៊ីហ្សេន (anaerobic bacteria)
-ត្រូវត្រួតពិនិត្យមើលចំនួនគ្រាប់ឈាមសឡាបានទៀងទាត់ក្នុងអំឡុងពេលប្រើឱសថនេះលើសរយៈពេល១០ថ្ងៃ
-ត្រូវប្រើឱសថនេះដោយប្រុងប្រយ័ត្នចំពោះអ្នកជំងឺដែលមានជំងឺប្រព័ន្ធសរសៃប្រសាទកណ្តាលនិងបរិមណ្ឌលធ្ងន់ធ្ងរ
-ចំពោះអ្នកជំងឺដែលត្រូវលាងឈាម ឱសថនេះត្រូវប្រើភ្លាមៗក្រោយពេលលាងឈាមរួច
-ចំពោះអ្នកជំងឺខ្សោយមុខងារតំរងនោម
-ចំពោះអ្នកជំងឺខ្សោយមុខងារថ្លើម ត្រូវបន្ថយកំរិតប្រើឱសថនេះមកត្រឹម១ភាគ៣ និងអាចប្រើតែ១ដងគត់ក្នុង១ថ្ងៃ
-ការប្រើឱសថនេះអាចធ្វើឲ្យថយចុះកំរិតអង់ហ្ស៊ីម Aspartate amino transferase
-ឱសថនេះអាចធ្វើឲ្យទឹកនោមឡើងពណ៌ខ្មៅ
-ឱសថនេះអាចប្រើលាយជាមួយសូលុយស្យុងសេរ៉ូមប្រៃ (normal saline) សេរ៉ូមផ្អែម (Dextrose 5%) ឬសេរ៉ូម dextrose-saline ឬសេរ៉ូម potassium chloride
-ដោយសារមិនមានការសិក្សាបញ្ជាក់ ត្រូវមានការយកចិត្តទុកដាក់នៅពេលប្រើឱសថនេះក្នុងរយៈពេលយូរលើសពីរយៈពេលប្រើធម្មតាដែលបានណែនាំ
-ការប្រើឱសថនេះអាចធ្វើអោយសំពាធឈាមថយចុះ ដូច្នេះត្រូវបន្ថយកំរិតប្រើរបស់ឱសថបញ្ចុះសំពាធឈាមពេលប្រើរួមផ្សំជាមួយឱសថ Metronidazole
-ការប្រើឱសថនេះច្រើននិងក្នុងរយៈពេលយូរអាចបណ្តាលឲ្យថយចុះខួរឆ្អឹង
-ត្រូវប្រុងប្រយ័ត្នពេលប្រើឱសថនេះជាមួយឱសថផ្សេងទៀតដូចជា warfarin, cyclosporin, lithium, 5-fluorouracil
-មិនត្រូវផឹកស្រាអំឡុងពេលព្យាបាលដោយឱសថនេះ
-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ
-មិនត្រូវប្រើឱសថហួសកាលបរិច្ឆេទប្រើប្រាស់

VI ផលរំខាន:
ផលរំខានកើតមានដោយកំរិតរបស់ឱសថនេះរួមមាន៖
-វិបត្តិប្រព័ន្ធទឹកឆ័ត្រនិងគ្រាប់ឈាម៖ កើនឡើងចំនួនគ្រាប់ឈាមស កើនឡើងចំនួន neutrophils ថយចុះចំនួនឈ្លាតែត
-វិបត្តិប្រព័ន្ធសុំសស៊ីរ៉ង្ហ៊ុ៖ ប្រតិកម្មអាណាហ្ស៊ីតុកទ៉ិក
-វិបត្តិអាហារូបត្ថម្ភនិងថ្លើមបូលីស៖ មិនសូវឃ្លាន
-វិបត្តិផ្លូវចិត្ត៖ លេវីវាយ វង្វេង
-វិបត្តិប្រព័ន្ធសរសៃប្រសាទ៖ វង្វេង ឈឺក្បាល ស្ពឹកដៃជើង រ៉ែងក ញ័រខ្លួន ផេងផោង រ៉ាលមុខ ប្រកាច់
-វិបត្តិតំហើញ៖ ឈឺក្នុងវ៉ាគ្ន
-វិបត្តិក្រពះ-ពោះវៀន៖ ភ្លាវក្នុងមាត់ ស្ពាតអណ្តាត រលាកមាត់ ចង្អោរ ក្អួត និងឈឺក្រពះ-ពោះវៀន រាក
-វិបត្តិស្បែកនិងជាលិកាក្រោមស្បែក៖ កន្ទួលមាស់លើស្បែក
-វិបត្តិថ្លើមប្រម៉ាត់៖ ប្រែប្រួលមុខងារថ្លើម រលាកថ្លើម រលាកក្រពេញប ង់ក្រេអា
-វិបត្តិឆ្អឹងសាច់ដុំនិងជាលិកាសន្ធាន៖ ឈឺសន្លាក់ ឈឺសាច់ដុំ
-វិបត្តិទឹកនោមនិងតំរងនោម៖ ទឹកនោមឡើងខ្មៅ

VII អន្តរកម្មឱសថ:
ត្រូវជៀសវាងប្រើរួមជាមួយឱសថដូចខាងក្រោម៖
-Alcohol
-Anticoagulant: Warfarin
-Lithium, phenobarbital, cyclosporin, 5-fluorouracil
-Busulfan

VIII ការរក្សាទុក:
-ត្រូវទុកនៅក្រោមសីតុណ្ហភាព ៣០℃
-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃ និងសំណើម
-ត្រូវទុកឲ្យផុតពីដៃកូនក្មេង។

IX កំរិត និងវិធីប្រើ:
❖ វិធីប្រើ
-ឱសថនេះប្រើចាក់ព្យួរតាមសរសៃឈាមតែប៉ុណ្ណោះ ក្នុងកំរិតបង្ហូរ 5ml ក្នុង១នាទី។ អ្នកជំងឺអាចប្រើឱសថនេះប្រភេទគ្រាប់ លេបតាមមាត់វិញបាននៅពេលណាដែលស្ថានភាពជំងឺបានធូរស្បើយ។
❖ កំរិតប្រើ
សំរាប់បង្ការជំងឺឆ្លងដោយសារមេរោគរស់ដោយគ្មានអុកស៊ីហ្សេន *(anaerobic bacteria)* និងពេលវះកាត់ប្រដាប់បន្តពូជស្ត្រី៖
ចំពោះមនុស្សពេញវ័យ៖
-កំរិតប្រើគឺ 500mg ប្រើភ្លាមៗមុនពេលការវះកាត់ ហើយប្រើម្តងទៀតរៀងរាល់៨ម៉ោងម្តង។ ការចាប់ផ្តើមប្រើកំរិត 200mg ឬ400mg លេបតាមមាត់រៀងរាល់៨ម៉ោងក្នុង១ថ្ងៃ នៅពេលអ្នកជំងឺអាចលេបតាមមាត់បាន។
ចំពោះកូនក្មេង៖
-ចំពោះកូនក្មេងអាយុក្រោម១២ឆ្នាំ៖ កំរិតប្រើគឺ 20mg ទៅ 30mg ក្នុងទម្ងន់ 1kg ប្រើតែ១ដងគត់ រយៈពេលពី១ម៉ោងទៅ២ម៉ោងមុនពេលការវះកាត់។
-ចំពោះទារកអាយុក្រោម៨០សប្តាហ៍៖ កំរិតប្រើគឺ 10mg ក្នុងទម្ងន់ 1kg ប្រើតែ១ដងគត់ មុនពេលការវះកាត់។
សំរាប់បង្ការជំងឺឆ្លងដោយសារមេរោគរស់ដោយគ្មានអុកស៊ីហ្សេន *(anaerobic bacteria)*៖
ការព្យាបាលត្រូវចាប់ផ្តើមដោយចាក់ព្យួរ តាមសរសៃឈាមប្រសិនបើអ្នកជំងឺមិនអាចលេបថ្នាំនេះតាមមាត់បាន។
ចំពោះមនុស្សពេញវ័យ៖
-កំរិតប្រើគឺ 500mg រៀងរាល់៨ម៉ោងម្តង ក្នុង១ថ្ងៃ។
ចំពោះកូនក្មេង៖
-ចំពោះកូនក្មេងអាយុលើសពី៨សប្តាហ៍ដល់ក្រោម១២ឆ្នាំ៖ កំរិតប្រើធម្មតាប្រចាំថ្ងៃគឺ 20mg ទៅ 30mg ក្នុងទម្ងន់ 1kg ប្រើតែ១ដងគត់ ឬប្រើកំរិត 7.5mg ក្នុងទម្ងន់ 1kg រៀងរាល់៨ម៉ោងម្តង។ កំរិតប្រើធម្មតាប្រចាំថ្ងៃអាចបង្កើនដល់ 40mg ក្នុងទម្ងន់ 1kg អាស្រ័យទៅតាមសភាពធ្ងន់ធ្ងររបស់ជំងឺឆ្លង។ ជាធម្មតា រយៈពេលព្យាបាលគឺ ៧ថ្ងៃ។
-ចំពោះកូនក្មេងអាយុក្រោម៨សប្តាហ៍៖ កំរិតប្រើធម្មតាប្រចាំថ្ងៃគឺ 15mg ក្នុងទម្ងន់ 1kg ប្រើតែ១ដងគត់ ក្នុង១ថ្ងៃ ឬប្រើកំរិត 7.5mg ក្នុងទម្ងន់ 1kg រៀងរាល់១២ម៉ោងម្តង។
-ចំពោះទារកអាយុក្រោម៨០សប្តាហ៍៖ មិនមានបញ្ហាក់កំរិតប្រើ តែត្រូវពិនិត្យមើលកំហាប់ metronidazole ក្នុងឈាមក្រោយព្យាបាលបានរយៈពេល២ទៅ៣ថ្ងៃក្រោយមក។
សំរាប់ព្យាបាលជំងឺឆ្លងក្នុងទ្វារមាសដោយសារបាក់តេរី៖
ចំពោះមនុស្សវ័យជំទង់៖
-កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ឬប្រើកំរិត 2000mg ប្រើតែ១ដងគត់ ក្នុង១ថ្ងៃ។
សំរាប់ព្យាបាលជំងឺឆ្លងក្នុងប្រដាប់បន្តពូជនិងផ្លូវបង្ហូរនោមដោយសារមេរោគ *Trichomonas*៖
ចំពោះមនុស្សពេញវ័យនិងមនុស្សវ័យជំទង់៖
-កំរិតប្រើគឺ 2000mg ប្រើតែ១ដងគត់ ក្នុង១ថ្ងៃ ឬប្រើកំរិត 200mg ចែកជា៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេល៧ថ្ងៃ ឬប្រើកំរិត 400mg ចែកជា២ដង ក្នុង១ថ្ងៃ សំរាប់រយៈពេល៥ទៅ៧ថ្ងៃ។
ចំពោះកូនក្មេង៖
-ចំពោះកូនក្មេងអាយុក្រោម១០ឆ្នាំ៖ កំរិតប្រើធម្មតាប្រចាំថ្ងៃគឺ 40mg ក្នុងទម្ងន់ 1kg លេបតាមមាត់ ប្រើតែ១ដងគត់ ឬប្រើកំរិត 15mg ទៅ 30mg ក្នុងទម្ងន់ 1kg ចែកជា២ទៅ៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេល៧ថ្ងៃ។ កំរិតប្រើគឺមិនត្រូវលើសពី 2000mg ក្នុងពេលប្រើម្តងឡើយ។
សំរាប់ព្យាបាលជំងឺឆ្លងក្នុងពោះវៀនដោយសារបាំរ៉ាស៊ីត៖
ចំពោះមនុស្សពេញវ័យអាយុលើសពី១០ឆ្នាំ៖
-កំរិតប្រើគឺ 2000mg ប្រើតែ១ដងគត់ ក្នុង១ថ្ងៃ សំរាប់រយៈពេល៣ថ្ងៃ ឬប្រើកំរិត 400mg ចែកជា៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេល ៥ថ្ងៃ ឬប្រើកំរិត 500mg ចែកជា២ដង ក្នុង១ថ្ងៃ សំរាប់រយៈពេល៧ទៅ១០ថ្ងៃ។
ចំពោះកូនក្មេង៖
-ចំពោះកូនក្មេងអាយុចន្លោះពី ៧ឆ្នាំ ទៅ ១០ឆ្នាំ៖ កំរិតណែនាំឲ្យប្រើគឺ 1000mg លេបតែ១ដងគត់ ក្នុង១ថ្ងៃ សំរាប់រយៈពេល៣ថ្ងៃ។
-ចំពោះកូនក្មេងអាយុចន្លោះពី ៣ឆ្នាំ ទៅ ៧ឆ្នាំ៖ កំរិតណែនាំឲ្យប្រើគឺពី 600mg ទៅ 800mg លេបតែ១ដងគត់ ក្នុង១ថ្ងៃ សំរាប់រយៈពេល៣ថ្ងៃ។
-ចំពោះកូនក្មេងអាយុចន្លោះពី ១ឆ្នាំ ទៅ ៣ឆ្នាំ៖ កំរិតណែនាំឲ្យប្រើគឺ 500mg លេបតែ១ដងគត់ ក្នុង១ថ្ងៃ សំរាប់រយៈពេល៣ថ្ងៃ ឬប្រើកំរិតពី 15mg ទៅ 40mg ក្នុងទម្ងន់ 1kg ចែកជា២ទៅ៣ដង ក្នុង១ថ្ងៃ។
សំរាប់ព្យាបាលជំងឺឆ្លងក្នុងពោះវៀនដោយសារមេរោគអាមីប (Amoebiasis) ៖
ចំពោះមនុស្សពេញវ័យអាយុលើសពី១០ឆ្នាំ៖
-កំរិតប្រើគឺ 400mg ទៅ 800mg ចែកជា៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេលពី៥ទៅ១០ថ្ងៃ។
ចំពោះកូនក្មេង៖
-ចំពោះកូនក្មេងអាយុចន្លោះពី ៧ឆ្នាំ ទៅ ១០ឆ្នាំ៖ កំរិតប្រើគឺ 200mg ទៅ 400mg ចែកជា៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេលពី ៥ទៅ១០ថ្ងៃ។
-ចំពោះកូនក្មេងអាយុចន្លោះពី ៣ឆ្នាំ ទៅ ៧ឆ្នាំ៖ កំរិតប្រើគឺ 100mg ទៅ 200mg ចែកជា៨ដង ក្នុង១ថ្ងៃ សំរាប់រយៈពេលពី ៥ទៅ១០ថ្ងៃ។
-ចំពោះកូនក្មេងអាយុចន្លោះពី ១ឆ្នាំ ទៅ ៣ឆ្នាំ៖ កំរិតប្រើគឺ 100mg ទៅ 200mg ចែកជា៨ដង ក្នុង១ថ្ងៃ សំរាប់រយៈពេលពី ៥ទៅ១០ថ្ងៃ ឬប្រើកំរិតពី 35mg ទៅ 50mg ក្នុងទម្ងន់ 1kg ចែកជា៣ដង ក្នុង១ថ្ងៃ សំរាប់រយៈពេលពី៥ទៅ១០ថ្ងៃ។
កំរិតប្រើគឺមិនត្រូវលើសពី 2400mg ក្នុង១ថ្ងៃឡើយ។
សំរាប់ព្យាបាលយល់បំបាត់មេរោគក្រពះ Helicobacter pylori ចំពោះអ្នកជំងឺកូនក្មេង ៖
ប្រើរួមផ្សំជាមួយឱសថអង់ទីប៊ីយ៉ូទិកផ្សេងទៀត។
-កំរិតប្រើគឺ 20mg ក្នុងទម្ងន់ 1kg និងមិនត្រូវប្រើលើសពី 500mg ចែកជា២ដងក្នុង១ថ្ងៃ សំរាប់រយៈពេលពី៧ទៅ១៤ថ្ងៃ។
ចំពោះមនុស្សចាស់៖
-មិនមានការបញ្ជាក់ជាក់លាក់លើការកំណត់ប្រែកំរិតប្រើរបស់ឱសថនេះចំពោះអ្នកជំងឺចាស់ជរាទេ។
➢ មុននឹងប្រើឱសថនេះ ត្រូវពិគ្រោះយោបល់ជាមួយគ្រូពេទ្យ ឬឱសថការី។

X លេខបញ្ជីកា: CAM N0237IP-17

XI ផលិតផ្លាយ: Abaris Healthcare Pvt. Ltd. (India)
បានបកប្រែ និងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង។
លេខ :១៧៨៨/១៧ ឱអបស ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៧